**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកៅស៊ូ**

ថ្ងៃ សុក្រ ១០កើត ខែ ចេត្រ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៣

លេខ: ៧៨ អក.ស

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២០

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំត្រីមាសទី១ ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត។

**ជូនភ្ជាប់** ៖ -របាយការណ៍ស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំត្រីមាសទី១ ឆ្នាំ២០២០...........ចំនួន០១ច្បាប់

-តារាងស្ថានភាពផលិតកម្មកៅស៊ូ និងតារាងស្ថានភាពធុរកិច្ចផលិតផលកៅស៊ូស្ងួត ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ ...............................ចំនួន០២ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានរបស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំត្រីមាសទី១ ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្តដោយសង្ខេបដូចខាងក្រោម៖

១-ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤០៥ ៤៨៥ហិកតា ក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន២៥០ ៧៥០ហិកតា ស្មើនឹង៦២% នឹងផ្ទៃដីថែទាំមានចំនួន១៥៤ ៧៣៥ហិកតា ស្មើនឹង៣៨%។

២-ផលិតផលជ័រកៅស៊ូក្នុងខែមានចំនួន១០ ៨២៤តោន ថយចុះចំនួន២ ៤២២តោន ស្មើនឹង១៨%ធៀបនឹងខែមុន នឹងបានថយចុះចំនួន៨៨១ ស្មើនឹង៨%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ ផលិតផលជ័រកៅស៊ូមកដល់ខែនេះមានចំនួន៥៣ ២៧២តោន បានកើនឡើងចំនួន៥ ០៨៩តោន ស្មើនឹង១១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៣-បរិមាណបញ្ចេញលក់ក្នុងខែមានចំនួន១១ ៧៥១តោន ថយចុះចំនួន២ ១១១តោន ស្មើនឹង១៥%ធៀបនឹងខែមុននឹងបានកើនឡើង៥៣តោនស្មើនឹង០,៥%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ បរិមាណបញ្ចេញលក់មកដល់ខែនេះមានចំនួន៥៣ ០៥៧តោន បានកើនឡើងចំនួន៤ ៨៦៥តោន ស្មើនឹង១០%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៤-តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែថ្លៃ១ ៣៩៧ដុល្លារ/តោន បានថយចុះចំនួន១៧ដុល្លារ/តោន ស្មើនឹង១,២១% ធៀបនឹងខែមុន នឹងបានកើនឡើង៣៥ដុល្លារ/តោនស្មើនឹង៣%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។ តម្លៃលក់កៅស៊ូមធ្យមគិតដល់ខែនេះថ្លៃ១ ៤២០ដុល្លារ/តោន បានកើនឡើងចំនួន១៤១ដុល្លារ/តោន ស្មើនឹង១១%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៥-តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅមាត់ចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៤ ៦០០-៤ ៨០០៛/គ.ក្រ (ពុំមានការកើនឡើងទេ ធៀបនឹងខែមុន) នឹងជ័រកក (DRC 50%) ថ្លៃ១ ៩៥០-២ ៥០០៛/គ.ក្រ បានថយចុះចំនួន ១០០៛/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

៦-ទិសដៅបន្ត៖ ខិតខំអនុវត្តទិសដៅការងារដែលបានគ្រោងទុកឲ្យបានសម្រេចលទ្ធផលល្អ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**ម៉ុល សុផា**

**ចម្លងជូន៖**
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក

"ដើម្បីជូនជ្រាប"

- នាយកដ្ឋានកិច្ចការរដ្ឋបាល កសក.
- នាយកដ្ឋានផែនការ និងស្ថិតិ កសក.
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- គ្រប់ចម្ការកៅស៊ូកសិឧស្សាហកម្ម

"ដើម្បីជ្រាប"

- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

# របាយការណ៍សរុប
# ស្តីពី
# ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត

## ១.សេចក្តីផ្តើម

ក្នុងឆ្នាំ២០២០ នេះអគ្គនាយកដ្ឋានកៅស៊ូ បានអនុវត្តការងារចម្បងៗ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ទាំងការងារចរន្ត ការងារអនុវត្តគម្រោងថវិកាតាមកម្មវិធី ការងារដាំដុះ ថែទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ច ទាំងកៅស៊ូគ្រួសារនិងកៅស៊ូកសិឧស្សាហកម្ម និងការងារផ្សេងៗទៀតបានដំណើរការជាធម្មតា។ ជាលទ្ធផលការងារសំខាន់ៗ ដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានក្នុងខែមីនាត្រីមាសទី១ ឆ្នាំ២០២០ មានខ្លឹមសារលម្អិតជូនដូចខាងក្រោម៖

## ២.លទ្ធផលការងារសម្រេចបាន

### ២.១ ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចកៅស៊ូ

#### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤០៥ ៤៨៥ ហិកតា ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ២៥០ ៧៥០ហិកតា ស្មើនឹង៦២% និងផ្ទៃដីថែទាំមានចំនួន១៥៤ ៧៣៥ហិកតា ស្មើនឹង៣៨%។

#### ២.១.២ ផលិតកម្ម

- ផលិតផលជ័រកៅស៊ូសម្រេចបានប្រចាំខែមីនា ឆ្នាំ២០២០ មានចំនួន១០ ៨២៤តោន បានថយចុះចំនួន២ ៤២២តោន ស្មើនឹង១៨%ធៀបនឹងខែមុននឹងបានថយចុះចំនួន៨៨១ស្មើនឹង៨%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- ផលិតផលជ័រកៅស៊ូសរុបគិតមកដល់ខែមីនា ត្រីមាសទី១ ឆ្នាំ២០២០ សម្រេចបានចំនួន៥៣ ២៧២តោនបានកើនឡើងចំនួន៥ ០៨៩តោន ស្មើនឹង១១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

#### ២.១.៣ ធុរកិច្ចកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូសម្រេចបានក្នុងខែមីនា ឆ្នាំ២០២០ មានចំនួន១១ ៧៥១តោន ថយចុះចំនួន២ ១១១តោន ស្មើនឹង១៥%ធៀបនឹងខែមុននឹងបានកើនឡើងចំនួន ៥៣តោនស្មើនឹង០,៥%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

- បរិមាណបញ្ចេញលក់សរុបគិតមកដល់ខែមីនា ត្រីមាសទី១ ឆ្នាំ២០២០ សម្រេចបានចំនួន៥៣ ០៥៧តោន កើនឡើងចំនួន៤ ៨៦៥តោន ស្មើនឹង១០%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

- តម្លៃលក់មធ្យមជ័រកៅស៊ូក្នុងខែមីនា ឆ្នាំ២០២០ មានចំនួន ១ ៣៩៧ដុល្លារ/តោន បានថយចុះចំនួន១៧ដុល្លារ/តោន ស្មើនឹង១,២១%ធៀបនឹងខែមុន នឹងបានកើនឡើង៣៥ដុល្លារ/តោនស្មើនឹង៣%ធៀបរយៈពេលដូចគ្នាឆ្នាំមុន។

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
National Road No.6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh, Cambodia
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email: gdr.maff@gmail.com

- តម្លៃលក់កៅស៊ូជាមធ្យមគិតមកដល់ខែមីនាត្រីមាសទី១ ឆ្នាំ២០២០ គឺ១ ៤២០ ដុល្លារ/តោន បានកើនឡើងចំនួន ១៤១ ដុល្លារ/តោន ស្មើនឹង១១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

- ក្នុងខែមីនា តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅមាត់ចម្ការ គឺទឹកជ័រ (DRC 100%) ថ្លៃ៤ ៦០០-៤ ៨០០រ/គ.ក្រ (ពុំមានការកើនឡើងទេ ធៀបនឹងខែមុន) និងជ័រកក (DRC 50%) ថ្លៃ១ ៩៥០-២ ៥០០រ/គ.ក្រ (ថយចុះចំនួន១០០រ/គ.ក្រ ធៀបនឹងខែមុន) អាស្រ័យតាមតំបន់។

## ២.២. ការងារចរន្តនិងការអនុវត្តគម្រោងសកម្មភាពថវិកាតាមកម្មវិធី

### ២.២.១. ការងារចរន្ត

- ប្រជុំរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុទ្ធពាក់ព័ន្ធវិស័យកៅស៊ូ
- បានចុះពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៩ ជាមួយក្រុមការងារ(ELC)របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានខេត្តក្រចេះ មណ្ឌលគីរី ត្បូងឃ្មុំ ស្ទឹងត្រែង ស្វាយរៀង កំពង់ចាម ព្រះវិហារ កំពត កោះកុង និងខេត្តព្រះសីហនុ
- បានចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារនៅស្រុកសៀមបូក ខេត្តស្ទឹងត្រែង
- បានចុះបើកវគ្គពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ នៅស្រុកអង្គរជុំ ខេត្តសៀមរាប
- បានចុះបើកវគ្គពង្រឹងសហគមន៍កសិកម្មកៅស៊ូគ្រួសារ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
- បានចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ នៅស្រុកស្នួល ខេត្តក្រចេះ
- ចុះពិនិត្យទីតាំងស្នើសុំបង្កើតការប្រមូលទិញជ័រកៅស៊ូគ្រួសារ នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ
- ចុះពិនិត្យតាមដានការអនុវត្តថវិកាកម្មវិធីលើចង្កោមសកម្មភាពទី១.៥.១ នៅខេត្តឧត្តរមានជ័យ
- ចុះបណ្តុះបណ្តាលនិងផ្សព្វផ្សាយអំពីទីផ្សាកៅស៊ូ នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម
- ផ្សព្វផ្សាយពត៌មានអំពីថ្លៃកៅស៊ូនៅទីផ្សារក្នុងនិងក្រៅប្រទេសតាមវិទ្យុ ដើម្បីជំរុញថ្លៃលក់ជ័រកៅស៊ូអោយបានប្រសើរ
- ប្រជុំពិនិត្យនិងសម្រេចព្រឹត្តិបត្រកៅស៊ូធម្មជាតិប្រចាំខែកុម្ភៈ និងលើកទិសដៅខែមីនា ឆ្នាំ២០២០
- បានប្រមូលទិន្នន័យ និងរៀបចំតម្លៃកៅស៊ូធម្មជាតិសម្រាប់ផ្សាយប្រចាំសប្តាហ៍តាមវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា(FM103.5)ចំនួន០៤ដងក្នុងមួយខែ(១សប្តាហ៍១ដង) និងបានផ្សាយបន្តផ្ទាល់ទៅតាមបណ្តាខេត្តចំនួន៤ខេត្ត គឺខេត្តបាត់ដំបង(FM106.3) ខេត្តកំពង់ចាម(FM99.3) ខេត្តកំពង់ធំ(FM104) និងខេត្តសៀមរាប(FM107) រៀងរាល់ថ្ងៃចន្ទ វេលាម៉ោង១០ព្រឹក
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀត។

### ២.២.២. ការចំណាយថវិកាតាមគម្រោងកម្មវិធី

ការចំណាយថវិកាក្នុងខែមីនា ត្រីមាសទី១ ឆ្នាំ២០២០ មានចំនួន ១៧១ ៤៣៥ ៩០៨រៀល។ បើគិតរហូតមកដល់ខែមីនានេះមានចំនួន៣៦៨ ៧២១ ៩០៨រៀល ស្មើនឹង១៧,៣៤ ភាគរយនៃផែនការ។

### ២.២.៣. ការប្រមូលចំណូលថវិកា

ការប្រមូលចំណូលថ្លៃឈ្នួលដីអវិនិយោគចម្ការកៅស៊ូរដ្ឋទាំង៧ ចម្ការកៅស៊ូរដ្ឋឡាបានសៀកខេត្តរតនគីរី និងក្រុមហ៊ុននីហរ័ណ អាហរ័ណកៅស៊ូ ក្នុងខែមីនាត្រីមាសទី១ ឆ្នាំ២០២០ ពុំទាន់មានទេ ។បើគិតរហូតមកដល់ខែមីនានេះអនុវត្តន៍បានចំនួន៣៥៥ ៥១៨ ៩៦០រៀល ស្មើនឹង២៧,១៩ភាគរយនៃផែនការ។

**៣. ទិសដៅបន្ត**

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធកៅស៊ូ
- បន្តចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូ ដល់កសិករកៅស៊ូគ្រួសារ
- បន្តចុះពង្រឹង និងចងក្រងសហគមន៍កសិករកៅស៊ូគ្រួសារ
- បន្តចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច
- បន្តអនុវត្តគម្រោងផែនការសកម្មភាពថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២០
- រៀបចំគម្រោងផែនការសកម្មភាពថវិកាកម្មវិធីឆ្នាំ២០២១
- បន្តខិតខំធ្វើទំនាក់ទំនងកិច្ចសហប្រត្តិបត្តិការជាមួយដៃគូរអភិវឌ្ឍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្រ្ត
- បន្តចុះពង្រឹង និងចងក្រងសហគមន៍ កសិករកៅស៊ូគ្រួសារសម្រាប់រៀបចំព្រឹត្តិបត្រប្រចាំខែ និងផ្សព្វផ្សាយតម្លៃកៅស៊ូធម្មជាតិតាមវិទ្យុប្រចាំសប្តាហ៍ និងលើគេហទំព័រហ្វេសប៊ុក របស់អគ្គនាយកដ្ឋានកៅស៊ូ
- បន្តរៀបចំផែនការសកម្មភាពការងារសំណើរគម្រោង និងទស្សនាទាននៃគម្រោងពាក់ព័ន្ធនឹងវិស័យឧស្សាហកម្មកៅស៊ូធម្មជាតិ
- បន្តអនុវត្តភារកិច្ចផ្សេងៗទៀត។

ថ្ងៃ ....... ១០កើត ខែ ........ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ....... ឆ្នាំ២០២០
**ប្រធាននាយកដ្ឋានរដ្ឋបាលនិងនីតិកម្ម**

ឃួន_ផល្លា

**បានឃើញនិងឯកភាព**
**ឧ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**
**អគ្គនាយករង**

ចាន់_វឌ្ឍនា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

## ស្ថានភាពផលិតកម្មកៅស៊ូប្រចាំត្រីមាសទី១ ឆ្នាំ២០២០

តារាងទី១

| ល.រ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) ចៀរជ័រ | ផ្ទៃដី ថែទាំ | ផ្ទៃដី សរុប | ឆ្នាំ២០១៩ ផលិតផល(តោន) ខែនេះ | ឆ្នាំ២០១៩ ផលិតផល(តោន) ដល់ខែនេះ | ឆ្នាំ២០១៩ បញ្ចេញលក់(តោន) ខែនេះ | ឆ្នាំ២០១៩ បញ្ចេញលក់(តោន) ដល់ខែនេះ | សន្និធិដើមឆ្នាំ | ឆ្នាំ២០២០ ផលិតផល(តោន) ខែនេះ | ឆ្នាំ២០២០ ផលិតផល(តោន) ដល់ខែនេះ | ឆ្នាំ២០២០ បញ្ចេញលក់(តោន) ខែនេះ | ឆ្នាំ២០២០ បញ្ចេញលក់(តោន) ដល់ខែនេះ | ប្រៀបធៀប ខែមុន ផ្ទៃដីសរុប ហិកតា | ខែមុន ផ្ទៃដីសរុប % | ខែមុន ផលិតផល តោន | ខែមុន ផលិតផល % | ខែមុន បញ្ចេញលក់ តោន | ខែមុន បញ្ចេញលក់ % | រយៈពេលដូចគ្នាឆ្នាំមុន ផលិតផល ខែនេះ តោន | ផលិតផល ខែនេះ % | ផលិតផល ដល់ខែនេះ តោន | ផលិតផល ដល់ខែនេះ % | បញ្ចេញលក់ ខែនេះ តោន | បញ្ចេញលក់ ខែនេះ % | បញ្ចេញលក់ ដល់ខែនេះ តោន | បញ្ចេញលក់ ដល់ខែនេះ % | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 670 | 132 | 801 | 14 | 96 | 50 | 50 | 158 | 14 | 61 | - | 15 | 0 | 0 | 1 | 6 | -15 | 0 | 0 | 0 | -34 | -36 | -50 | 0 | -35 | -70 | 204 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 11.971 | 3.262 | 15.233 | 270 | 2.566 | 215 | 3.362 | 1.093 | 330 | 2.629 | 269 | 1.596 | 0 | 0 | -374 | -53 | -120 | -31 | 60 | 22 | 62 | 2 | 54 | 25 | -1.767 | -53 | 2.126 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 1.118 | 1.247 | 2.365 | - | 276 | - | 336 | 21 | - | 220 | - | 210 | 0 | 0 | -62 | 0 | -210 | 0 | 0 | 0 | -56 | -20 | 0 | 0 | -126 | -38 | 31 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 6.103 | 1.912 | 8.015 | - | 715 | 77 | 955 | 618 | 17 | 665 | 197 | 994 | 0 | 0 | -197 | -92 | -318 | -62 | 17 | 100 | -50 | -7 | 120 | 156 | 39 | 4 | 289 |
| 5 | ក្រុមហ៊ុនស៊ីហ្វូ វ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | 306 | 2.418 | 2.724 | 10 | 16 | - | - | 365 | 8 | 55 | - | - | 0 | 0 | -7 | -47 | 0 | 0 | -2 | -17 | 39 | 241 | 0 | 0 | 0 | 0 | 420 |
| 6 | ក្រុមហ៊ុនស៊ីហ្វូ រីសសស លីមីធីត(ស្នួល) | 4.174 | 76 | 4.250 | - | 561 | 86 | 800 | 2.248 | - | 376 | 250 | 1.194 | 0 | 0 | 0 | 0 | -263 | -51 | 0 | 0 | -185 | -33 | 164 | 192 | 395 | 49 | 1.429 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេសិនណល | 3.908 | 278 | 4.186 | - | 567 | 210 | 420 | 756 | - | 414 | - | 925 | 0 | 0 | -34 | 0 | -400 | 0 | 0 | 0 | -153 | -27 | -210 | 0 | 505 | 120 | 245 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 3.312 | 1.570 | 4.882 | 51 | 242 | 55 | 305 | 613 | 44 | 181 | 150 | 380 | 0 | 0 | 17 | 63 | 150 | 100 | -7 | -13 | -61 | -25 | 95 | 173 | 75 | 25 | 414 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង+មេមសហែក) | 1.918 | 1.119 | 3.037 | 13 | 120 | 95 | 195 | 380 | 12 | 127 | 60 | 189 | 0 | 0 | -20 | -64 | 60 | 100 | -1 | -9 | 7 | 6 | -35 | -37 | -6 | -3 | 318 |
| 10 | ក្រុមហ៊ុនក្រេក(ខេមបូឌា) ខូអិលធីឌី | 4.639 | 159 | 4.798 | 349 | 1.526 | 210 | 1.470 | 550 | - | 945 | 525 | 1.155 | 0 | 0 | -346 | 0 | 105 | 25 | -349 | 0 | -581 | -38 | 315 | 150 | -315 | -21 | 340 |
| | សរុប ក | 38.120 | 12.173 | 50.293 | 705 | 6.684 | 998 | 7.892 | 6.802 | 424 | 5.672 | 1.451 | 6.657 | 0 | 0 | -1.022 | -71 | -1.011 | -41 | -281 | -40 | -1.011 | -15 | 453 | 45 | -1.235 | -16 | 5.817 |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 79.361 | 114.727 | 194.088 | 4.500 | 16.900 | 4.300 | 16.100 | 3.653 | 4.400 | 20.000 | 4.400 | 19.400 | 0 | 0 | -600 | -12 | -400 | -8 | -100 | -2 | 3.100 | 18 | 100 | 2 | 3.300 | 20 | 4.253 |
| | សរុប I=ក+ខ | 117.481 | 126.901 | 244.382 | 5.205 | 23.584 | 5.298 | 23.992 | 10.455 | 4.824 | 25.672 | 5.851 | 26.057 | 0 | 0 | -1.622 | -25 | -1.411 | -19 | -381 | -7 | 2.089 | 9 | 553 | 10 | 2.065 | 9 | 10.070 |
| | II. កៅស៊ូគ្រួសារ | 133.269 | 27.834 | 161.103 | 6.500 | 24.600 | 6.400 | 24.200 | 7.076 | 6.000 | 27.600 | 5.900 | 27.000 | 0 | 0 | -800 | -12 | -700 | -11 | -500 | -8 | 3.000 | 12 | -500 | -8 | 2.800 | 12 | 7.676 |
| | សរុបរួម I+II | 250.750 | 154.735 | 405.485 | 11.705 | 43.184 | 11.698 | 48.192 | 17.531 | 10.824 | 53.272 | 11.751 | 53.057 | 0 | 0 | -2.422 | -18 | -2.111 | -15 | -881 | -8 | 5.089 | 11 | 53 | 0,5 | 4.865 | 10 | 17.746 |

បញ្ជាក់៖

(១) ផ្ទៃដីសរុបមានចំនួន ៤០៥ ៤៨៥ ហត ( ផ្ទៃដីចៀរជ័រ ២៥០ ៧៥០ ហត ថែទាំ ១៥៤ ៧៣៥ហត) ។

(២) ផលិតផលសរុបចំនួន ១០ ៨២៤ តោន បានថយចុះចំនួន ២ ៤២២ តោន ស្មើនឹង(១៨%) ធៀបនឹងខែមុននិងបានថយចុះចំនួន៨៨១ តោនស្មើនឹង(៨%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៣) រហូតមកដល់ខែមីនាត្រីមាសទី១ ឆ្នាំ២០២០ ផលិតផលសរុបចំនួន ៥៣ ២៧២ តោន បានកើនឡើងចំនួន៥ ០៨៩តោន ស្មើនឹង(១១%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៤) ការបញ្ចេញលក់សរុបចំនួន១១ ៧៥១តោន បានថយចុះចំនួន ២ ១១១ តោន ស្មើនឹង(១៥%)ធៀបនឹងខែមុននិងបានកើនឡើងចំនួន៥៣តោនស្មើនឹង(0,៥%)ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៥) រហូតមកដល់ខែមីនា ត្រីមាសទី១ឆ្នាំ២០២០ ការបញ្ចេញលក់សរុបចំនួន៥៣ ០៥៧តោន បានកើនឡើងចំនួន៤ ៨៦៥ តោន ស្មើនឹង(១០%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

(៦)សន្និធិចុងគ្រាមានចំនួន១៧ ៧៤៦ តោន។

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

ចាន់_វឌ្ឍនា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

យួន_ផល្លា

ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២០
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

## តារាងស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំត្រីមាសទី១ ឆ្នាំ២០២០

តារាងទី២

| ល.រ | ចម្ការកៅស៊ូ | មីនា ២០១៩ | | | | | | មីនា ២០២០ | | | | | | ធៀបខែមុន | | | | ធៀបរយៈពេលដូចគ្នានៅឆ្នាំមុន | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | បរិមាណ | | តម្លៃមធ្យម | | បរិមាណ | | | | តម្លៃមធ្យម | | | |
| | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | បរិមាណ(តោន) | | ទឹកប្រាក់($) | | តម្លៃមធ្យម($/តោន) | | ខែនេះ | | ខែនេះ | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | |
| | | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | តោន | % | $/តោន | % | តោន | % | តោន | % | $/តោន | % | $/តោន | % |
| I. កៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 50 | 50 | 64,000 | 64,000 | 1,280 | 1,280 | | 15 | | 14,500 | 0 | 967 | -15 | 0 | -967 | 0 | -50 | 0 | -35 | -70 | -1,280 | 0 | -313 | -24 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 215 | 3,362 | 291,556 | 4,295,885 | 1,353 | 1,278 | 269 | 1,596 | 407,452 | 2,384,028 | 1,514 | 1,494 | -120 | -30.90 | -34 | -2.19 | 54 | 25 | -1,767 | -53 | 160 | 12 | 216 | 17 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | | 336 | | 432,600 | 0 | 1,288 | | 210 | | 275,940 | 0 | 1,314 | -210 | 0 | -1,314 | 0 | 0 | 0 | -126 | -38 | 0 | 0 | 27 | 2 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 77 | 955 | 106,368 | 1,250,336 | 1,385 | 1,310 | 197 | 994 | 311,904 | 1,539,406 | 1,585 | 1,549 | -318 | -61.75 | 0 | 0.01 | 120 | 156 | 39 | 4 | 200 | 14 | 239 | 18 |
| 5 | ក្រុមហ៊ុនស៊ីហ្វ រ៉ាប់ប៊ើ លីមីតធីត(រតនគិរី) | | 0 | | 0 | 0 | 0 | | 0 | | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| 6 | ក្រុមហ៊ុនស៊ីហ្វ វិសសស៍ លីមីធីត(ស្នួល) | 86 | 800 | 112,948 | 956,728 | 1,320 | 1,197 | 250 | 1,194 | 324,480 | 1,607,180 | 1,300 | 1,346 | -263 | -51 | -22 | -1.70 | 164 | 192 | 395 | 49 | -20 | -2 | 149 | 12 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ីនធើណេស៊ិនណល | 210 | 420 | 297,150 | 569,730 | 1,415 | 1,357 | | 925 | | 1,315,125 | 0 | 1,422 | -400 | 0.00 | -1,334 | 0.00 | -210 | 0 | 505 | 120 | -1,415 | 0 | 65 | 5 |
| 8 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ចម្ការអណ្តូង) | 55 | 305 | 69,100 | 345,400 | 1,256 | 1,132 | 150 | 380 | 185,500 | 472,100 | 1,237 | 1,242 | 150 | 100 | 1,237 | 100 | 95 | 173 | 75 | 25 | -20 | -2 | 110 | 10 |
| 9 | ក្រុមហ៊ុនអានម៉ាឌី គ្រុប(ពាមជាំង) | 95 | 195 | 125,400 | 234,900 | 1,320 | 1,205 | 60 | 189 | 72,702 | 231,124 | 1,208 | 1,224 | 60 | 100 | 1,208 | 100 | -35 | -37 | -6 | -3 | -112 | -9 | 20 | 2 |
| 10 | ក្រុមហ៊ុនក្រេក(ខេមបូឌា) ខូអិលធីឌី | 210 | 1,470 | 291,900 | 1,886,430 | 1,390 | 1,283 | 525 | 1,155 | 724,500 | 1,600,200 | 1,380 | 1,385 | 105 | 25 | 45 | 3.37 | 315 | 150 | -315 | -21 | -10 | -1 | 102 | 8 |
| | **សរុប ក** | **998** | **7,892** | **1,358,422** | **10,036,010** | **1,361** | **1,272** | **1,451** | **6,657** | **2,026,538** | **9,439,604** | **1,397** | **1,418** | **-1,011** | **-41.07** | **-17** | **-1.21** | **453** | **45** | **-1,235** | **-16** | **35** | **3** | **146** | **12** |
| ខ | ចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច | 4,300 | 16,100 | 5,853,937 | 20,617,290 | 1,361 | 1,281 | 4,400 | 19,400 | 6,146,104 | 27,546,787 | 1,397 | 1,420 | -400 | -8.33 | -17 | -1.21 | 100 | 2 | 3,300 | 20 | 35 | 3 | 139 | 11 |
| | សរុបI=ក+ខ | 5,298 | 23,992 | 7,212,359 | 30,653,299 | 1,361 | 1,278 | 5,851 | 26,057 | 8,172,642 | 36,986,391 | 1,397 | 1,419 | -1,411 | -19.43 | -17 | -1.21 | 553 | 10 | 2,065 | 9 | 35 | 3 | 142 | 11 |
| | II. កៅស៊ូគ្រួសារ | 6,400 | 24,200 | 8,712,836 | 30,980,502 | 1,361 | 1,280 | 5,900 | 27,000 | 8,241,366 | 38,347,854 | 1,397 | 1,420 | -700 | -11 | -17 | -1.21 | -500 | -8 | 2,800 | 12 | 35 | 3 | 140 | 11 |
| | **សរុបI+II** | **11,698** | **48,192** | **15,925,195** | **61,633,801** | **1,361** | **1,279** | **11,751** | **53,057** | **16,414,008** | **75,334,244** | **1,397** | **1,420** | **-2,111** | **-15.2** | **-17** | **-1.21** | **53** | **0.5** | **4,865** | **10** | **35** | **3** | **141** | **11** |

**បញ្ជាក់៖**

១. ក្នុងខែមីនា ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន១១ ៧៥១តោន បានថយចុះចំនួន២ ១១១តោន(=-១៥,២%)បើធៀបនឹងខែមុន ប៉ុន្តែបានកើនឡើងចំនួន៥៣តោន(=+0,៥%)បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

២. ក្នុងខែមីនា ឆ្នាំ២០២០ តម្លៃលក់មធ្យមគឺ១ ៣៩៧ដុល្លារ/តោន បានថយចុះចំនួន១៧ដុល្លារ/តោន(=-១,២១%)ធៀបនឹងខែមុន ប៉ុន្តែបានកើនឡើងចំនួន៣៥ដុល្លារ/តោន (=+៣%)បើធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

៣. ក្នុងត្រីមាសទី១ ឆ្នាំ២០២០ បរិមាណបញ្ចេញលក់សរុបមានចំនួន៥៣ ០៥៧តោន បានកើនឡើង៤ ៨៦៥តោន (=+១០%)ធៀបរយៈពេលដូចគ្នាឆ្នាំ២០១៩។

៤. ក្នុងត្រីមាសទី១ ឆ្នាំ២០២០ តម្លៃលក់មធ្យមគឺ១ ៤២០ដុល្លារ/តោន បានកើនឡើងចំនួន១៤១ដុល្លារ/តោន (=+១១%) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩។

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

យុន ភក្តដា

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ហ៊ិន-សាផន

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ [illegible] ព.ស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០២០
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ

# តម្លៃប្រមូលទិញជ័រកៅស៊ូពីកសិករកៅស៊ូគ្រួសារ

*ខែមីនា ឆ្នាំ២០២០*

| ល.រ | ខេត្ត | សប្តាហ៍ទី ១ | | | | | | សប្តាហ៍ទី ២ | | | | | | សប្តាហ៍ទី ៣ | | | | | | សប្តាហ៍ទី ៤ | | | | | | តម្លៃមធ្យមខែ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | | | ជ័រកក | | | ទឹកជ័រ | ជ័រកក |
| | | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | $/គ.ក្រ | ធៀបសប្តាហ៍មុន (៛/គ.ក្រ) | ៛/គ.ក្រ | ៛/គ.ក្រ |
| ១ | កំពង់ចាម | 4,900 | 1.20 | → 0 | 2,000 | 0.49 | → 0 | 4,700 | 1.16 | ↓ 200 | 1,900 | 0.47 | ↓ 100 | | | | | | | | | | | | | 4,800 | 1950 |
| ២ | ត្បូងឃ្មុំ | 4,900 | 1.20 | ↑ 100 | 2,000 | 0.49 | → 0 | 4,700 | 1.16 | ↓ 200 | 1,900 | 0.47 | ↓ 100 | | | | | | | | | | | | | 4,800 | 1950 |
| ៣ | កំពង់ធំ | 4,600 | 1.13 | → 0 | 2,300 | 0.56 | → 0 | 4,600 | 1.13 | → 0 | 2,300 | 0.57 | → 0 | សម្រាកចៀរជ័រ | | | | | | | | | | | | 4,600 | 2300 |
| ៤ | ត្បូងឃ្មុំ | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥ | ក្រចេះ | 4,600 | 1.13 | → 0 | 2,500 | 0.61 | → 0 | 4,600 | 1.13 | → 0 | 2,500 | 0.62 | → 0 | | | | | | | | | | | | | 4,600 | 2500 |
| ៦ | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | | | | | |
| | តម្លៃមធ្យម | **4,760** | 1.17 | ↑ 120 | **2,160** | **0.53** | ↓ 7 | **4,680** | **1.15** | ↓ 80 | **2,120** | **0.52** | ↓ 40 | | | | | | | | | | | | | 4,720 | 2,140 |
| | អត្រាប្តូរប្រាក់ធនាគារជាតិនៃកម្ពុជា | 4,080 | | | | | | 4,055 | | | | | | | | | | | | | | | | | | | |

**បញ្ជាក់៖**

*ប្រភព: ពីអ្នកប្រមូលទិញតាមតំបន់*

*ទឹកជ័រ: គិតជាស្ងួត (DRC)*

*ជ័រកក: DRC ≅ 50%*

ក្នុងខែមីនា ឆ្នាំ២០២០ តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារនៅមាត់ចម្ការ គឺទឹកជ័រ(DRC 100%) ថ្លៃ៤៦០០៛-៤៨០០៛/គ.ក្រ (ពុំមានការកើនឡើងទេ បើធៀបនឹងខែមុន) និងជ័រកក(DRC 50%) ថ្លៃ១៩៥០៛-២៥០០៛/គ/ក្រ (ថយចុះ១០០៛/គ.ក្រ ធៀបខែមុន) អាស្រ័យតាមតំបន់។

ថ្ងៃ [illegible] ១០រោច ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២០
អ្នកធ្វើតារាង

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ

ហ៊ិន-សាផន

បានឃើញ និងឯកភាព
ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ
អគ្គនាយករង

យុន ភក្កដា